ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់

រវាង

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

និង

អង្គការវីវើលអនលូស

ស្តីពី

## ការលើកកម្ពស់ និងការការពារសិទ្ធិការងាររបស់ពលករ ទេសន្តរប្រវេសន៍កម្ពុជាដែលមានជំនាញទាប

# បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសម្តែង នូវបំណងប្រាថ្នា ក្នុងការរួមសហការជាមួយអង្គការវីវើលអនលូស ក្នុងការលើកកម្ពស់ និងការការពារសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍កម្ពុជាមានជំនាញទាប ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ដើម្បីការពារពីការរំលោភបំពានផ្សេងៗ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើជួញដូរមនុស្ស។

**ដោយយល់ថា៖** ការជួញដូរមនុស្ស ការរំលោភបំពានគ្រប់ទម្រង់ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មពលករទេសន្តរប្រវេសន៍កម្ពុជា ដែលកំពុងធ្វើការនៅប្រទេសថៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនលូស ចាំបាច់ត្រូវសហការគ្នាក្នុងការបង្ការទប់ស្កាត់ និងការពារសិទ្ធិរបស់ពួកគាត់ និងក្រុមគ្រួសារ។

**ដោយហេតុថា៖** អង្គការវីវើលអនលូសមានបេសកកម្មក្នុងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈគម្រោង "សិទ្ធិការងារ ៖ ការលើកកម្ពស់ និងការការពារសិទ្ធិការងាររបស់ពលករទេសន្តរ-ប្រវេសន៍កម្ពុជាដែលមានជំនាញទាប ក្នុងការបង្ការទប់ស្កាត់ពីការរំលោភបំពានដោយទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចផ្សេងទៀត នៃអំពើជួញដូរមនុស្ស" ទើបចាំបាច់ត្រូវសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឱ្យស្របទៅនឹងផែនការយុទ្ធសាស្រ្តជាតិ(គ.ជ.ប.ជ) ច្បាប់គោលនយោបាយ បទដ្ឋានគតិយុត្តជាតិ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសថៃ។

## ប្រការ១

## គោលបំណង

អនុស្សរណៈយោគយល់នេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងគណៈកម្មា-ធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការ វីវើលអនលូស ក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវសិទ្ធិការងារ និងបរិយាកាសការងារប្រកបដោយសន្តិសុខ និងសុវត្ថិភាព សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលគ្មានជំនាញ និងមានជំនាញទាបនៅប្រទេសថៃ ជាពិសេសស្រ្តី។

## ប្រការ ២
## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

ដើម្បីឱ្យការអនុវត្តកិច្ចព្រមព្រៀងនេះទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានព្រមព្រៀងដូចខាងក្រោម ៖

- អនុញ្ញាតឱ្យអង្គការ វីវើលអនលូស បំពេញការងាររបស់ខ្លួន ដោយអនុវត្តឱ្យស្របទៅតាមច្បាប់និងបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជា។
- សម្របសម្រួលដល់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) គោលដៅនៃគម្រោង (សៀមរាប និងកំពង់ចាម) ដើម្បីចូលរួមជាមួយសកម្មភាពនានារបស់អង្គការ វីវើលអនលូស ដូចជាការប្រជុំក្រុមផ្សព្វផ្សាយពីសិទ្ធិការងារ ការកសាងសមត្ថភាព សិក្ខាសាលា និងសន្និសីទផ្សេងៗ ដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ស្តីពីអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងរាយការណ៍ពីលទ្ធផលដែលទទួលបានជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- អនុញ្ញាតឱ្យអង្គការវីវើលអនលូសចូលរួមប្រជុំលេខាធិការដ្ឋានខេត្តគោលដៅទាំងពីរ ដើម្បីចែករំលែកបច្ចុប្បន្នភាពទិន្នន័យដែលជាលទ្ធផលគម្រោង ក៏ដូចជាកង្វល់ បញ្ហាប្រឈម និងសំណូមពរនានាដែលត្រូវរួមគ្នាដោះស្រាយ។
- អនុញ្ញាតឱ្យអង្គការវីវើលអនលូសចូលរួមក្នុងកិច្ចប្រជុំដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងសមិទ្ធផលការងារដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ជានាចែករំលែកបទពិសោធន៍នានា និងសមិទ្ធផលការងារដែលទទួលបាន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពការងារ ក្នុងការងារបង្ការទប់ស្កាត់ ការរំលោភបំពានផ្សេងៗ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរមនុស្ស និងកិច្ចការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។

## ប្រការ៣
## ការទទួលខុសត្រូវរបស់អង្គការ វីវើលអនលូស

អង្គការវីវើលអនលូសទទួលខុសត្រូវដូចខាងក្រោម៖

- គ្រប់គ្រងមូលនិធិដែលផ្តល់ដោយសហភាពអឺរ៉ុប ដើម្បីបម្រើដល់ការអនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាព ចំគោលដៅ និងគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួនចូលរួមរាល់សកម្មភាពណាមួយដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។
- ខេត្តគោលដៅដែលត្រូវអនុវត្តសកម្មភាពរបស់គម្រោង "សិទ្ធិការងារ" គឺខេត្តសៀមរាប និងខេត្តកំពង់ចាម ។

- ប្រតិបត្តិរាល់សកម្មភាពជាមនុស្សធម៌ ដើម្បីជួយការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរ-ប្រវេសន៍កម្ពុជា ស្របតាមផែនការយុទ្ធសាស្ត្រជាតិរបស់ គ.ជ.ប.ជ និងគោលនយោបាយរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគោលការណ៍ នៃកិច្ចសហការស្របតាមច្បាប់ជាតិ។
- សហការ និងគាំទ្រដល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ចំណេះដឹង ជំនាញ បទពិសោធន៍ដែលបានចែករំលែករវាងមន្ត្រីកម្ពុជា និងថៃ ដល់អាជ្ញាធរមូលដ្ឋាន ជនបង្គោលសហគមន៍ និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនចំណេះដឹងស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ និងសិទ្ធិការងារ។
- គាំទ្រដល់ការប្រមូល និងចែករំលែកព័ត៌មានសំខាន់ៗអំពីតម្រូវការចាំបាច់ដល់ពលករទេសន្តរ-ប្រវេសន៍ រួមទាំងករណីរំលោភបំពាននានា។
- ពង្រឹងភាពជាដៃគូជាមួយ គ.ខ.ប.ជ ខេត្តគោលដៅរបស់គម្រោង ដើម្បីសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាន ពាក់ព័ន្ធនឹងសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ អំពើជួញដូរមនុស្ស និងការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ព្រមទាំងធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងឆ្នាំ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្តីពី សកម្មភាពដែលបានអនុវត្ត សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមដែលបានជួបប្រទះ ។
- ចូលរួមតែសកម្មភាពការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ និងសកម្មភាពមនុស្សធម៌ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុខុមាលភាពសង្គមប្រយោជន៍សាធារណៈ។
- ជៀសវាងដាច់ខាតការចូលរួមពាក់ព័ន្ធគ្រប់សកម្មភាពនយោបាយ ។
- ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្តីពីការផ្លាស់ប្តូរណាមួយដូចជា អាសយដ្ឋាន អ្នកតំណាង ឬនាយកគម្រោង ។

## ប្រការ៤

## ការដោះស្រាយវិវាទ

រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈយោគយល់នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ វីវើលអនលូស ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ ។

## ប្រការ ៥

## អវសានប្បញ្ញត្តិ

អនុស្សរណៈយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ហើយអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីភាគីទាំងពីរ។

អនុស្សរណៈនៃការយោគយល់នេះ អាចនឹងត្រូវបានព្យួរ ឬបញ្ចប់ដោយភាគីណាមួយ។ ក្នុងករណីនេះ អនុស្សរណៈយោគយល់ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៥...ខែ...........ឆ្នាំ ២០២១

| | |
|---|---|
| **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** | **តំណាងអង្គការ** |
| **អនុប្រធានអចិន្ត្រៃយ៍** | **វេវើលអនលូស** |
| | **(WE WORLD ONLUS)** |
| **ជូ_ប៊ុនអេង** | We World<br># 49, St. 302, Boeung Keng Kang I, Khan Chamkamon, Phnom Penh (Cambodia)<br>Tel (+855) 23 5550348 - P.O. Box No. 131 |

# ឧបសម្ព័ន្ធ

## សង្ខេបអំពីគម្រោង

- ឈ្មោះស្ថាប័ន ៖ អង្គការ វីវើល អនលូស (WE WORLD ONLUS)
- ប្រភេទស្ថាប័ន ៖ អង្គការអន្តរជាតិ
- បានចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តន៍គម្រោង៖ ផ្ទះលេខ៣១២ ផ្លូវសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
- ទូរស័ព្ទ ៖ (+៨៥៥) ២៣ ៥៥៥ ០៣៨៨ / ៦៣ ៩០០ ០៤៥
- អ៊ីម៉ែល ៖ cambodia.admin@weworld.it
- ឈ្មោះគម្រោង ៖ សិទ្ធិការងារ
- ថវិកាអនុវត្តគម្រោង ៖ USD ៣៥៤,៩៤២.៣៤ (បីរយហាសិបបួនពាន់ ប្រាំបួនរយសែសិបពីរដុល្លារសហរដ្ឋអាម៉េរិក និងសាមសិបបួនសេន)
- កាលបរិច្ឆេទចាប់ផ្តើម ៖ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ (បានចុះកិច្ចសហការនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១)
- កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២
- ទីកន្លែងអនុវត្តគម្រោង ៖ ខេត្តសៀមរាប និងខេត្តកំពង់ចាម
- ចំនួនបុគ្គលិកបរទេស ៖ ១ នាក់
- ចំនួនបុគ្គលិកខ្មែរ ៖ ៨ នាក់ ។

# KINGDOM OF CAMBODIA

## NATIONAL RELIGION KING

# MEMORANDUM OF UNDERSTANDING

BETWEEN

NATIONAL COMMITTEE FOR COUNTER TRAFFICKING IN PERSONS

AND

WE WORLD ONLUS

ON

# PROMOTING AND PROTECTING THE LABOUR RIGHTS OF LOW SKILLED CAMBODIAN MIGRANT WORKERS

## PREAMBLE

**WHEREAS** the National Committee for Counter Trafficking, herein thereafter referred to as NCCT, has expressed its desire to collaborate with WE WORLD ONLUS in promoting and protecting the labour rights of low skilled Cambodian migrant workers working in Thailand to prevent abuse, labour exploitation, and human trafficking.

**WHEREAS** NCCT and WE WORLD ONLUS need to co-operate in preventing all forms of abuses, labour exploitation, human trafficking and for the protection of the rights of Cambodian migrant workers working in Thailand and their family members.

**WHEREAS** WE WORLD ONLUS embarks upon a mission to prevent human trafficking through the project entitled ***'RIGHT-TO-WORK: promoting and protecting the labour rights of low skilled Cambodian migrant workers'*** in preventing them from the abuses by any form of exploitation or trafficking in persons, therefore, WE WORLD ONLUS needs to co-operate with NCCT in accordance with the National Strategic Plan for Counter Trafficking in Persons, laws, policies, national legal standards, and collaborations between Cambodia and Thailand.

## ARTICLE 1
## Objective

This Memorandum of Understanding aims to increase cooperation between NCCT and We World Onlus in contributing to improve labour rights and safe and secure working environment for unskilled and low skilled Cambodian migrant workers in Thailand, in particular to women.

## ARTICLE 2
## Responsibilities of the National Committee for Counter Trafficking (NCCT)

In order for the implementation of this MOU to be successful and highly effective, the National Committee for Counter Trafficking has agreed as follows:

- Allow WE WORLD ONLUS to carry out its activities in accordance with the laws and regulations of the Royal Government of Cambodia.
- Coordinate with Provincial Committee for Counter Trafficking in persons (PCCT) in the target areas of the project (Siemreap and Kampong Cham provinces) to participate in the activities of WE WORLD ONLUS such as Labour Rights Corners (LRC), meetings, capacity buildings, workshops and conferences to improve the understanding among people at the community level on human trafficking, safe migration and to report the achieved results to NCCT.
- Allow WE WORLD ONLUS to attend the meetings of the two target provincial secretariats (PCCT) in order to share up-to-date project results, as well as concerns, challenges, and suggestions that need to be addressed together.
- Allow WE WORLD ONLUS to participate in the meetings organized by the NCCT to share information, experiences, and achievements at both national and sub-national levels.

- Ensure that all experiences and the achievements to counter trafficking at national and sub-national levels are shared broadly for the purpose of improving the effectiveness of preventing abuses, labor exploitation, trafficking and of protecting the rights of Cambodian Migrant workers.

## ARTICLE 3

## Responsibilities of WE WORLD ONLUS

WE WORLD ONLUS has the responsibilities as follow:

- WE WORLD ONLUS shall manage the fund supported by the European Union (EU) for the purpose of effective implementation of all the activities under the project and shall comply with Laws and Regulations of Cambodia, and WE WORLD ONLUS shall not allow its staff to participate in any activity that could be harmful to national security, national unity, culture and tradition of Cambodia.
- The target provinces to implement **Right to Work** project activities are Siemreap and Kampong Cham provinces.
- WE WORLD ONLUS shall implement all activities in a humanitarian manner to provide protection and promotion of rights of Cambodian migrant workers in accordance with National Strategic Plan for Counter Trafficking in Persons and its policies upholding the principles of cooperation according to Cambodia's national laws.
- Cooperate and support capacity building, knowledge, skills, and experience sharing between Cambodian and Thai officials to local authorities, community mobilizers and civil society organizations to improve the knowledge on labour migration management and labour rights.
- Support collection and dissemination of important information about main needs of migrant workers and cases of abuses.
- Strengthen the partnership with PCCT in the two targeted provinces to facilitate information exchange in relation to labour rights of migrant workers, human trafficking and safe migration and to submit quarterly, semester, and annual reports on activities implemented, key achievements and challenges to the NCCT.
- Shall only engage in activities for the purpose of protection of migrant workers' rights and benefits and other humanitarian activities as allowed by the Royal Government of Cambodia for the sake of social wellbeing and public benefits.
- Shall not engage in any political activities.
- Shall notify to the NCCT in written format about any changes regarding its address, Representative or Project Director.

**ARTICLE 4**

**Dispute Resolution**

All differences arising between NCCT and WE WORLD ONLUS related to the interpretation or implementation of the MoU shall be resolved amicably through peaceful negotiation between both parties.

**ARTICLE 5**

**Final Provision**

This Memorandum of Understanding shall enter into effect on the date of signing by both parties and shall remain effective for three (3) years and can be extended upon agreement between both parties.

This Memorandum of Understanding may be suspended or terminated by either party. The suspension or termination shall take effect sixty (60) days following the date of written notice to the other party.

This Memorandum of Understanding is done in duplicate in Khmer and English. All texts shall be equally authentic. In case of any divergence of interpretation, the Khmer text shall prevail.

Phnom Penh, ......14 June 2021......

**National Committee for Counter Trafficking**
**Permanent Vice-Chairperson**

CHOU BUN ENG

**WE WORLD ONLUS Representative**
**Country Representative**

We World
# 49, St. 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh (Cambodia)
Tel (+855) 23 5550348 - P.O. Box No. 131

## ANNEX

### PROJECT SUMMARY

- Organization Name : **WE WORLD ONLUS**
- Organization Type : Foreign Non-government organization
- Registered at Ministry of Foreign Affair and International Cooperation on 05 November 2019.
- Address of Project Implementation: House No. 312, Sala lodge road, Sala Kamreuk commune, Siem Reap town, Siem Reap province.
- Tel : (+855) 23 555 0348 / 63 900 045
- Email : Cambodia.admin@weworld.it
- Project Name : Right to Work
- Project Budget : 354,942.34 USD
- Project start date : 01 February 2019
- Project end date : 31 January 2022
- Project target areas : Siem Reap and Kampong Cham provinces
- Foreigner staff : 1 staff
- Cambodian staff : 8 staff